# ការសម្ភាសន៍របស់បងស្រី សៅ អ៊ន់

កៈ អ្នកសម្ភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសម្ភាសន៍ សៅ អ៊ន់

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងស្រី សៅ អ៊ន់

សង្ខេបៈ បងស្រីសៅ អ៊ន់ គាត់មានអាយុសែសិបពីរឆ្នាំ គាត់បានកើតនៅឆ្នាំរោង ហើយគាត់កើតនៅភូមិច្រឡោង ឃុំដំរិស ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ហើយគាត់មានបងប្អូនចំនួន៥នាក់ ហើយគាត់ជាកូនទីបីនៅក្នុងក្រុមគ្រួសារ។ នៅក្នុងក្រុមគ្រួសារដែលមានជីវភាពមិនសូវល្អ គាត់ត្រូវចេញទៅស៊ីឈ្នួលគេជាមួយឪពុកគាត់តាំងពីនៅតូចដូច្នេះគាត់មិនបានរៀនបានច្រើនគេ។ ជីវិតរបស់គាត់ ពេលដែលគាត់នៅជាមួយឪពុកម្តាយមានភាពងាយស្រួលច្រើន តែក្រោយគាត់បានរៀបការ គាត់មានការលំបាកច្រើន ហើយមានបន្ទុកគ្រួសារច្រើនដែលគាត់ត្រូវទទួលខុសត្រូវ។ គាត់បានតស៊ូច្រើនណាស់ដើម្បីជំនះលើឧបសគ្គដែលគាត់បានជួបជារៀងរាល់ថ្ងៃ។ធ្វើឡើងនៅភូមិច្រឡោង ឃុំដំរិល ស្រុកអូរាំឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី១៧ ខែ០៤ ឆ្នាំ២០១៨។

កៈ អញ្ចឹងដំបូង ជំរាបសួរបងស្រី។

ខៈ ជំរាបសួរ។

កៈ ខ្ញុំបាទឈ្មោះគង់ ចាន់ណាក់ មកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដែលធ្វើឡើង ដោយសាកលវិទ្យាល័យ ប៊ី វាយ យូ ដែលនៅសហរដ្ឋអាមេរិច ដោយសារសកលវិទ្យាល័លមាន គោលបំណាងដើម្បីរក្សាប្រវត្តិរបស់ប្រជាជនខ្មែរយើង ដើម្បីទុកអោយកូនចៅជំនាន់ក្រោយរបស់ពួក យើងពួកគេអាចស្គាល់ពីប្រវត្តិរបស់ដូនតានឹងឪពុកម្តាយរបស់ពួកគេ។ ហើយសំរាប់ការសម្ភាសន៍ យើងធ្វើឡើងនៅថ្ងៃទី១៧ ខែ០៤ ឆ្នាំ២០១៨។ ហើយសំរាប់ការសម្ភាសន៍នឹងយើងនឹងថតសំលេង និងថតរូបភាពបងស្រីដើម្បីផ្ញើរទៅកាន់សកលវិទ្យាល័យ ប៊ី វាយ យូ ដើម្បីសកលវិទ្យាល័យអាច ដាក់រូបភាពនិងសំលេងរបស់បងស្រីនៅលើវេបសាយរបស់សកលវិទ្យាល័យ។

ហើយអញ្ចឹង តើ បងស្រីយល់ព្រមអោយយើងយកសំលេង និងរូបភាពរបស់បងស្រីដាក់លើវេបសាយរបស់ សកលវិទ្យាល័យទេបងស្រី?

ខ៖ មានអី ព្រមអោយយកទៅដាក់តើ។

ក៖ អរគុណច្រើនបងដែលអនុញ្ញាតិអោយយើងយកសំលេងនិងរូបថតបងស្រីដាក់នៅលើវេបសាយ របស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង សំរាប់បងស្រី តើបងស្រីមានឈ្មោះពេញអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះ អ៊ន់។

ក៖ ឈ្មោះ អ៊ន់! ហើយចុះ បងស្រីមានត្រកូលអ្វីដែលបងស្រី?

ខ៖ ត្រកូលរបស់ខ្ញុំ សៅ។

ក៖ អញ្ចឹង ឈ្មោះពេញរបស់បងស្រី សៅ អ៊ន់។

ខ៖ ចា៎!

ក៖ ហើយអញ្ចឹង តើបងស្រីមានឈ្មោះហៅក្រៅទេ បងស្រី?

ខ៖ អត់មានផង មានតែឈ្មោះមួយនឹងទេ។

ក៖ ហើយអញ្ចឹង កាលបងស្រីនៅក្មេងតូចៗ តើគេហៅបងស្រីឈ្មោះអ្វីដែរ?

ខ៖ គេមិនដែលហៅអីទេ គេហៅតែឈ្មោះមួយនឹងទេ។

ក៖ ហើយអញ្ចឹងគេហៅតែឈ្មោះមួយនឹងរហូតតែម្តងហ៎! ហើយសំរាប់បងស្រី តើសព្វថ្ងៃនេះបងស្រី មានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុសែសិបពីរឆ្នាំហើយ។

ក៖ បងស្រីមានអាយុសែសិបពីរឆ្នាំហើយ។ ហើយអញ្ចឹង បងស្រីនៅចាំថា តើបងស្រីបានកើតនៅ ឆ្នាំណាទេបងស្រី?

ខ៖ ខ្ញុំមិនចាំទេ តែគ្រាន់តែដឹងថាឆ្នាំដែលគេកៀរយើងទៅសង្គ្រាម។

ក៖ អញ្ចឹងបងស្រីអាយុសែសិបពីរឆ្នាំ! អញ្ចឹងបងស្រីប្រហែលកើតនៅក្នុងឆ្នាំ មួយពាន់ប្រាំបួនរយ ចិតសិបប្រាំមួយ។ ហើយសំរាប់ឆ្នាំខ្មែរ តើបងស្រីនៅចាំទេថា បងស្រីបានកើតនៅក្នុងឆ្នាំណាដែរ? (ឆ្នាំខ្មែរ ឆ្នាំ ជូត ខាល ថោះ រោង ម្សាញ់ ......)

ខ៖ ខ្ញុំកើតឆ្នាំរោង។

ក៖ ហើយអញ្ចឹង សំរាប់បងស្រី តើបងស្រីកើតនៅខេត្តណាដែរ?

ខ៖ ខ្ញុំកើតនៅខេត្តកំពង់ចាម តែឥឡូវគេបានប្តូរទៅជាខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង តើបងអាចជួយប្រាប់ឈ្មោះភូមិ ឃុំ ស្រុក ដែលបងស្រីបានកើតបានទេ?

ខ៖ ខ្ញុំបានកើតនៅ ភូមិច្រឡោង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង សំរាប់បងស្រី តើបងស្រីមានបងប្អូនចំនួនប៉ុន្មាននាក់?

ខ៖ ខ្ញុំមានបងប្អូនចំនួន៥នាក់។

ក៖ ហើយអញ្ចឹង សំរាប់បងស្រី តើបងស្រីជាកូនទីប៉ុន្មានដែរ បងស្រី?

ខ៖ ខ្ញុំជាកូនទីបីនៅក្នុងក្រុមគ្រួសារ។

ក៖ ហើយអញ្ចឹង តើបងស្រីមានបងប្អូនស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខ៖ ខ្ញុំមានបងប្អូនស្រីបួននាក់ ហើយនឹងប្រុសមួយនាក់។

ក៖ ស្រីបួន ប្រុសតែមួយទេ។ ហើយអញ្ចឹង តើបងស្រីអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនរបស់បងស្រីទាំងអស់បានទេ?

ខ៖ បងគេបង្អស់ឈ្មោះអៀច ហើយបានបងបន្ទាប់ឈ្មោះអៀ ហើយមានបន្ទាប់មកគឺខ្ញុំនឹងហើយ ហើយបន្ទាប់មកទៀតឈ្មោះវិបុល ហើយចុងក្រោយគេឈ្មោះអឿន។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹងបងស្រីមាននៅចាំសាច់រឿងពីពួកគាត់ទេ?

ខ៖ សាច់រឿងពួកគាត់កំសត់ណា គាត់ទៅធ្វើការស្រុកគេ ដើររកស៊ីស្រុកគេកំសត់ណាស់ ធ្វើការ រោងចក្រអាឈើ វេទនាណាស់ យើងពួនយើងអី រត់គេចពីគេ គេដេញចាប់ដេញអី វេទនាណាស់។

ក៖ ហើយអញ្ចឹង សំរាប់បងស្រី កាលបងស្រីនៅក្មេងៗ
តើបងស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់បងស្រី?

ខ៖ មានចូលចិត្តធ្វើអីទេ មានតែរត់លេងជាមួយគ្នា
ហើយនឹងធ្វើការងារផ្ទះជាមួយគ្នាអីនឹង។

ក៖ ហើយអញ្ចឹង បងស្រីមានធ្លាប់ទៅធ្វើស្រែចំការជាមួយនឹងបងប្អូនរបស់បងស្រីទេ?

ខ៖ ធ្លាប់តើ ធ្លាប់ទៅស្ទូងដកជាមួយគ្នា។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ បងប្អូនរបស់បងស្រី
តើពួកគាត់រស់នៅឯណាដែរបងស្រី?

ខ៖ សព្វថ្ងៃនេះពួកគាត់នៅនឹង នៅជុំគ្នាទាំងអស់គ្នានឹង។

ក៖ អញ្ចឹងមានន័យថាបងប្អូនរបស់បងនៅផ្ទះនឹងទាំងអស់គ្នា។ ហើយអញ្ចឹង
សំរាប់សព្វថ្ងៃនេះ តើពួកគាត់ទាំងអស់គ្នា ធ្វើការងារអ្វីដែរ បងស្រី?

ខ៖ ពួកគាត់ទាំងអស់គ្នាធ្វើស្រែ ជាកសិករ។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់បងស្រី តើគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ សៅ។

ក៖ ឈ្មោះ សៅ! ហើយចុះ តើបងស្រីមានស្គាល់ត្រកូលរបស់គាត់ទេ បងស្រី?

ខ៖ ត្រកូលរបស់ឪពុកខ្ញុំ គឺ ភិន។

ក៖ ហើយអញ្ចឹង ឪពុកបងស្រី គាត់ឈ្មោះ ភិន សៅ។

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង សំរាប់ម្ដាយរបស់បងស្រីវិញ តើគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខ៖ ម្ដាយរបស់ខ្ញុំឈ្មោះ តែម។

ក៖ ឈ្មោះ តែម! ហើយចុះ តើម្ដាយបងស្រី មានត្រកូលអ្វីដែរ បងស្រី?

ខ៖ ត្រកូល គេវ។

ក៖ ហើយអញ្ចឹង ម្ដាយរបស់បងស្រី គាត់ឈ្មោះ គេវ តែម។ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើឪពុករបស់បងស្រី គាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ឪពុករបស់ខ្ញុំគាត់មានអាយុចិតសិបឆ្នាំគត់។

ក៖ ចិតសិបឆ្នាំគត។ ហើយចុះសំរាប់ម្ដាយរបស់បងស្រី តើសព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ម្ដាយរបស់ខ្ញុំគាត់មានអាយុចិតសិបបួនឆ្នាំហើយ។

ក៖ អូ! គាត់មានអាយុចិតសិបបួនឆ្នាំហ៎! ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ ឪពុកម្ដាយរបស់បងស្រី ពួកគាត់រស់នៅជាមួយបងស្រីដែរមែនទេ?

ខ៖ ហ្នឹងហើយ ពួកគាត់រស់នៅនឹងជាមួយយើងទាំងអស់គ្នា។

ក៖ ហ្នឹងហើយ នៅជុំកូនជុំចៅល្អណាតើបងស្រី។ ហើយអញ្ចឹង បងស្រីមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកម្ដាយបងស្រីទេ?

ខ៖ ខ្ញុំមិនចាំទេ។

ក៖ អញ្ចឹងឪពុកបងស្រីអាយុចិតសិបឆ្នាំគត់ ចឹងគាត់ប្រហែលកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំបី។ ហើយសំរាប់ម្ដាយរបស់បងស្រី គាត់មានអាយុចិតសិបបួនឆ្នាំ ចឹងគាត់ប្រហែលកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបបួន ដោយសារតែម្ដាយរបស់បងស្រីគាត់បងរបស់ឪពុករបស់បងស្រីបួនឆ្នាំ។ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់បងស្រី តើពួកគាត់ប្រកបមុខរបរអ្វើដើម្បីចិញ្ចឹមជីវិតដែរ បងស្រី?

ខ៖ ពួកគាត់មានធ្វើអីទេ ពួកគាត់ធ្វើតែស្រែចំការទេ តែឥឡូវធ្វើតែស្រែទេ ពីមុនមានចំការតែឥឡូវអត់មានទេ ចឹងធ្វើតែស្រែមួយមុខទេ។

ក៖ អូ! អញ្ចឹងពួកគាត់ធ្វើតែស្រែទេ។ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់បងស្រី គាត់ជាមនុស្សយ៉ាងម៉េចដែរបងស្រី?

ខ៖ ឪពុកម្ដាយរបស់ខ្ញុំគាត់ជាមនុស្សល្អ គាត់មិនដែលចេះធ្វើបាបកូនចៅទេ គាត់ជាមនុស្សស្លូតបូត ហើយបង្រៀនកូនចៅអោយចេះគោរពចាស់ទុំ ហើយមិនអោយធ្វើអំពើដែលគេស្អប់ខ្ពើម។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹងបងស្រីមាននៅចាំពីសាច់រឿង ឬមួយខ្សែជីវិតរបស់ពួកគាត់ទេ?

ខ៖ រឿងខ្សែជីវិតរបស់ឪពុកម្ដាយនៅចាំខ្លះ និងមិនចាំខ្លះ។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹង
តើបងស្រីអាចជួយប្រាប់ពីរឿងដែលបងស្រីនៅចាំពីខ្សែជីវិតរបស់ឪពុកម្ដាយរបស់បងស្រី
បានទេ?

ខ៖ ពីមុនមកពួកគាត់ដើរស៊ីឈ្នួលគេដែលនឹង ធ្វើរបចាក់រូបអីនឹងយកទៅលក់ចឹងទៅ
ជួនកាលទៅគាត់ទៅរែកទឹក រែកដីអោយគេចឹងទៅ
ហើយជួនកាលគាត់ទៅដឹកអូសដាក់ក្នុងឡអោយគេ គាត់ទៅស៊ីឈ្នួលគេ
ខ្ញុំធ្លាប់ទៅជាមួយគាត់។

ក៖ ហើយអញ្ចឹង បងស្រីមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់បងស្រីទេ?

ខ៖ ជីដូនជីតាខាងឪពុករបស់ខ្ញុំឈ្មោះ យាយឡាយ តាភិន។

ក៖ យាយឡាយ តាភិន! ហើយអញ្ចឹង សព្វថ្ងៃនេះពួកគាត់នៅរស់
ឬមួយពួកគាត់ស្លាប់អស់ហើយ បងស្រី?

ខ៖ ពួកគាត់ស្លាប់អស់ហើយ។

ក៖ ហើយអញ្ចឹង បងស្រីនៅចាំថា តើជីដូនជីតាខាងឪពុករបស់បងស្រី
គាត់កើតនៅពេលណាទេ?

ខ៖ មិនចាំទេ ពួកគាត់ស្លាប់តាំងពីខ្ញុំនៅតូចមកម្លេះ ចឹងហើយខ្ញុំមិនចាំទេ។
តែគ្រាន់តែលឺម៉ែប្រាប់ថា យាយកើតឆ្នាំឆ្លូវ ហើយតាវិញកើតឆ្នាំរកា។

ក៖ អូ! អញ្ចឹង យាយកើតឆ្នាំខ្មែរឆ្នាំឆ្លូត ហើយតាវិញកើតឆ្នាំរកា។ ហើយអញ្ចឹង
តើបងស្រីមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់បងស្រីទេ?

ខ៖ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំ គាត់ឈ្មោះតាគេវ យាយត្រួន។

ក៖ តាគេវ យាយត្រួន! ហើយអញ្ចឹង បងស្រីមាននៅចាំថា
ពួកគាត់បានកើតនៅពេលណាទេ?

ខ៖ តាកើតនៅឆ្នាំមមែ ហើយយាយកើតនៅឆ្នាំថោះ។

ក៖ ហើយអញ្ចឹង សំរាប់ជីដូនជីតាខាងម្ដាយរបស់បងស្រី
តើពួកគាត់បានកើតនៅកន្លែងណាដែរ បងស្រី?

ខ៖ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំគាត់កើតនៅនឹងតើ ពួកគាត់កើតនៅភូមិនឹងទេ។

ក៖ អូ! ពួកគាត់កើតនៅភូមិនឹងទាំងអស់គ្នាហ៎បងស្រី។
ចឹងមានន័យថាពួកគាត់កើតនៅទីនេះទាំងអស់គ្នាមិនបានទៅណាទេ។ ហើយអញ្ចឹង
បងស្រីមានដឹងរឿងខ្សែជីវិតរបស់ពួកគាត់ទេ?

ខ៖ ចាំមិនបានទេ ព្រោះអីខ្ញុំនៅតូចៗមានទាន់ដឹងអីទេ។

ក៖ ហើយអញ្ចឹង
សំរាប់ក្រុមគ្រួសាររបស់បងស្រីបានរស់នៅខេត្តនឹងអស់រយៈពេលប៉ុន្មានឆ្នាំហើយ?

ខ៖ សំរាប់ក្រុមគ្រួសារខ្ញុំម៉ងនៅទីនេះយូរហើយ បើនិយាយទៅខ្ញុំនៅទីអស់ម្ភៃពីរឆ្នាំហើយ។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹង
បងស្រីមានសាច់ញាត្តិដែលរស់នៅក្រៅពីប្រទេសកម្ពុជាយើងទេ?

ខ៖ អត់មានទេ មាននៅតែក្នុងប្រទេសយើងនឹងទេ
មិនដែលមាននរណាទៅនៅក្រៅប្រទេសទេ។

ក៖ អញ្ចឹងមានតែនៅស្រុកខ្មែរយើងទេ។ ហើយអញ្ចឹង
តើបងស្រីរៀបអាពាហ៍ពិពាហ៍ហើយឬនៅទេ បងស្រី?

ខ៖ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ហើយ។

ក៖ ហើយអញ្ចឹង បងស្រីបានរៀបអាពាហ៍ពិពាហ៍ពេលណាដែរបងស្រី?

ខ៖ មិនដឹងទេ តែគ្រាន់តែចាំថាឆ្នាំដែលខ្ញុំរៀបការនឹង ស្រូវស្រេកអស់រលីង
ហើយត្រូវនឹងឆ្នាំរក។

ក៖ ឆ្នាំរក! ហើយអញ្ចឹង ពេលដែលបងស្រីរៀបអាពាហ៍ពិពាហ៍នឹង
តើបងស្រីមានអាយុប៉ុន្មានហើយ?

ខ៖ ពេលដែលខ្ញុំរៀបអាពាហ៍ពិពាហ៍នឹង ខ្ញុំមានអាយុដប់ប្រាំបួនឆ្នាំ។

ក៖ ហើយអញ្ចឹង មកដល់សព្វថ្ងៃនេះ
តើបងស្រីបានរៀបអាពាហ៍ពិពាហ៍បានប៉ុន្មានឆ្នាំហើយ?

ខ៖ មកដល់សព្វថ្ងៃនេះខ្ញុំរៀបអាពាហ៍ពិពាហ៍បានម្ភៃពីរឆ្នាំហើយ។

កៈ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹង បានរៀបចំឡើងដោយឪពុកម្ដាយរបស់បងស្រី ឬមួយបងស្រីជាអ្នករៀបចំឡើងដោយខ្លួនឯង?

ខៈ ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយយើងមានគូស្រករ។

កៈ ហើយអញ្ចឹង ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង មានដូចជាថ្លៃជំនួនទេបងស្រី?

ខៈ មានតើ កាលនឹងថ្លៃជំនួនចំនួនប្រាំរយដូល្លារ។

កៈ ហើយអញ្ចឹង សំរាប់បងស្រី បងស្រីគិតថា ជីវិតមុនរៀបការ
ហើយនឹងជីវិតក្រោយការរៀបការ មានភាពខុសគ្នាទេបងស្រី?

ខៈ ខុសគ្នាឆ្ងាយណាស់ កាលនៅជាមួយម្ដាយរបស់យើងមិនសូវពិបាកទេ
ដល់ពេលយើងរៀបការ ហើយទៅនៅជាមួយប្ដីវាពិបាក
ដោយសារយើងត្រូវទទួលខុសត្រូវច្រើននៅក្នុងក្រុមគ្រួសារ។

កៈ ហ្នឹងហើយ! យើងត្រូវធ្វើការដើម្បីចិញ្ចឹមជីវិតរបស់យើង។ ហើយអញ្ចឹង
បងស្រីអាចជួយប្រាប់បានទេ
ពេលដែលបងស្រីបានជួបជាមួយនឹងបងប្រុសជាលើកដំបូង?

ខៈ ពេលដែលខ្ញុំប្ដីរបស់ខ្ញុំលើកដំបូងពេលដែលទៅមើលបុណ្យល្ខោន ហើយបានជួបគ្នា
ហើយស្គាល់គ្នាតាំងពីពេលនឹងមក
ហើយក្រោយមកទៀតគាត់ក៏អោយឪពុកម្ដាយរបស់គាត់ចូលមកស្ដី ដណ្ដឹងខ្ញុំទៅ។

កៈ អញ្ចឹងមានន័យថា នាំគ្នាទៅមើលល្ខោន
ហើយអញ្ចឹងបងស្រីហើយបងប្រុសបានជួបគ្នា ហើយនិយាយលេងជាមួយគ្នា
ហើយគាត់ក៏នាំម៉ែឪគាត់អោយមកស្ដីដណ្ដឹងបងស្រី។ ហើយអញ្ចឹង សំរាប់
ចំណងអាពាហ៍ពិពាហ៍របស់បងស្រីហើយនឹងប្ដីរបស់បង មានកូនប៉ុន្មាននាក់ហើយ?

ខៈ ខ្ញុំមានកូនចំនួនពីរនាក់ហើយ។

កៈ ហើយបងស្រីមានកូនប្រុសប៉ុន្មាន ហើយស្រីប៉ុន្មាន?

ខៈ ខ្ញុំមានកូនប្រុសម្នាក់ ហើយស្រីម្នាក់។

កៈ អូ! កូនប្រុសមួយ ហើយស្រីមួយ។ ហើយអញ្ចឹង
តើបងស្រីអាចជួយប្រាប់ឈ្មោះកូនទាំងពីរនាក់របស់បងស្រីបានទេ?

ខៈ កូនទីមួយឈ្មោះរដ្ឋា ហើយកូនទីពីរឈ្មោះណារី។

កៈ ហើយអញ្ចឹងកូនបងស្រីឈ្មោះរដ្ឋា សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ រដ្ឋាសព្វថ្ងៃនេះគាត់មានអាយុម្ភៃពីរឆ្នាំហើយ។

កៈ រដ្ឋាកូនបងស្រីនឹង គាត់ជាកូនស្រីមែនទេបងស្រី?

ខៈ បងគេបង្អស់នឹងជាកូនប្រុស។

កៈ ហើយកូនទីពីរគាត់ឈ្មោះណារី។ ហើយអញ្ចឹង សំរាប់ណារី
សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយបងស្រី?

ខៈ សព្វថ្ងៃនេះគាត់មានអាយុដប់ប្រាំបួនឆ្នាំហើយ។

កៈ ហើយអញ្ចឹង បងស្រីមាននៅចាំឆ្នាំដែលកូនទាំងពីររបស់បងស្រីបានកើតទេ?

ខៈ នៅចាំតើ កូនទីមួយនឹងគាត់កើតឆ្នាំកុរ ហើយកូនទីរនឹងគាត់កើតឆ្នាំថោះ។

កៈ ហើយអញ្ចឹងសំរាប់បងស្រី តើបងស្រីចេះអាននិងសរសេរអក្សរខ្មែរទេ បងស្រី?

ខៈ អត់ចេះសោះតែម្តង។

កៈ ហើយអញ្ចឹង បងស្រីចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ?

ខៈ អត់ចេះតែម្តងនឹង។

កៈ ហើយអញ្ចឹង បងស្រីអត់ដែលបានចូលរៀននៅក្នុងសាលាទេបងស្រី?

ខៈ បានរៀនតើ គ្រាន់តែបានរៀនតិចតួច រវល់តែមើលក្របីផង មើលគោផង
ហើយទៅដឹកអុស ជាមួយពុកផងលែងបានរៀនបណ្តោយ។

កៈ ហើយសំរាប់បងស្រីរៀនបានតិចតួចនឹង តើបងស្រីបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ
បងស្រី?

ខៈ កាលនោះខ្ញុំរៀនបានត្រឹមថ្នាក់ទីពីរនឹង។

កៈ ហើយអញ្ចឹង កាលដែលបងស្រីបានរៀននឹង
តើបងស្រីបានរៀននៅសាលាណាដែរបងស្រី?

ខៈ ខ្ញុំរៀននៅសាលាដំរិលយើងនឹង។

កៈ ហើយអញ្ចឹង បងស្រីមាននៅចាំឈ្មោះសាលាដំរិលនឹងទេ?

ខ៖ មិនចាំទេ ព្រោះអីគេរើធ្វើថ្មីអស់ហើយនឹង។

ក៖ អូ! គេរើធ្វើថ្មី ហើយគេដូរឈ្មោះថ្មី។ ហើយអញ្ចឹង
បងស្រីមានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយគ្នាដែរឬទេ?

ខ៖ ធ្លាប់មាន តែថាឥឡូវបែកគ្នាអស់ហើយ។

ក៖ ហើយអញ្ចឹង ពួកគាត់មានឈ្មោះអ្វីដែរបង?

ខ៖ មិត្តភក្តិច្រើនណាស់ តែឥឡូវបែកគ្នាអស់ទៅ ភ្លេចអស់ហើយ។

ក៖ អត់ទេ ខ្ញុំអោយបងរាប់ប្រាប់មួយនាក់ពីរដែលជិតស្និតជាងគេចឹងណា?

ខ៖ អ្នកដែលជិតស្និតមែនទែន ឈ្មោះតាំង ហើយនឹងឈ្មោះសៀ។

ក៖ ហើយអញ្ចឹង បងស្រីដឹងទេថា ពួកគាត់រាល់ថ្ងៃរស់នៅណាដែរ បងស្រី?

ខ៖ ទេមិនដឹងទេ ឥឡូវនឹងមិនដឹងថាគេទីរកស៊ីដល់ណាទេ។

ក៖ អូ!
អញ្ចឹងមានន័យថាពួកគាត់ចេញទៅរកស៊ីនៅឆ្ងាយៗអស់ហើយមិនបានទាក់ទងគ្នាទៀតទេ
។ ហើយអញ្ចឹង សំរាប់មិត្តជិតស្និតរបស់បងស្រី តើពួកគាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ពួកគាត់មានអាយុប្រហាក់ប្រហែលនឹងខ្ញុំដែលនឹង ព្រោះអីយើងរៀនជាមួយគ្នា។

ក៖ ហើយអញ្ចឹងមានន័យអាយុពួកគាត់ហើយនឹងបងស្រី មានអាយុប្រហាក់ប្រហែលគ្នា។
ហើយ  អញ្ចឹង តើបងស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយមិត្តភក្តិរបស់បងស្រី
កាលបងស្រីនៅក្មេងៗ?

ខ៖ កាលនៅក្មេងៗចូលចិត្តលេងបិទពួនជាមួយគ្នា ចូលចិត្តលេងលោតអន្ទាក់ជាមួយគ្នា។

ក៖ មានធ្លាប់ដែលទៅស្រែចំការ ហើយធ្វើស្រែចំការជាមួយមិត្តភក្តិរបស់បងស្រីទេ?

ខ៖ មិនដែលទៅទេ ធ្លាប់តែទៅធ្វើស្រែចំការជាមួយម៉ែឪ
តែសំរាប់មិត្តភក្តិមិនដែលទៅជាមួយគ្នាទេ។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះបងស្រីមានធ្វើស្រែចំការទេ?

ខ៖ សព្វថ្ងៃនេះមានធ្វើស្រែបន្តិច បើចំការវិញអត់មានទេ។

ក៖ ហើយអញ្ចឹង ក្រៅពីធ្វើស្រែ តើបងស្រីមានធ្វើការអ្វីដើម្បីចិញ្ចឹមជីវិតដែរឬទេបងស្រី?

ខ៖ ក្រៅពីធ្វើស្រែ ដើរស៊ីឈ្នួលគេដើម្បីចិញ្ចឹមជីវិត បើធ្វើស្រែតែបន្តិចនឹងហូបម៉េចគ្រាន់។

ក៖ តើបងស្រី ស៊ីឈ្នួលធ្វើអ្វីដែរបងស្រី?

ខ៖ ស៊ីឈ្នួលតាមរោចចក្រអាឈើ។

ក៖ ហើយអញ្ចឹង បងស្រីគិតថា តាំងពីក្មេងរហូតមកដល់ពេលនេះ តើជីវិតរបស់បងស្រីមានការផ្លាស់ប្តូរដែរឬទេ?

ខ៖ ផ្លាស់ប្តូរច្រើនណាស់។

ក៖ ហើយអញ្ចឹង សំរាប់ម្ហូបវិញ តើបងស្រីចូលចិត្តហូបម្ហូបអ្វីជាងគេ បងស្រី?

ខ៖ សំរាប់ខ្ញុំចូលចិត្តសម្លរម្ជូរគ្រឿងជាងគេ។

ក៖ សម្លរម្ជូរគ្រឿងហ៎បង! ហើយសំរាប់ល្បែងប្រជាប្រិយខ្មែរវិញ តើបងចូលចិត្តលេងល្បែងអ្វីជាងគេតាំងពីក្មេងរហូតមកដល់ពេលនេះ?

ខ៖ អត់ចូលចិត្តលេងទេល្បែងនោះ។

ក៖ អត់ទេបងស្រី សំរាប់ល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង បោះអង្គុញ ទាញព្រ័ត្រ?

ខ៖ ខ្ញុំចូលចិត្តរាំជាងគេ។

ក៖ អូ! បងចូលចិត្តរាំវង់ រាំក្បាច់អីចឹងហ៎! ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ តើបងស្រីមានបទចម្រៀងណាដែលបងស្រីស្រឡាញ់ ហើយចូលចិត្តស្តាប់ ហើយរៀនច្រៀងតាមអីចឹង តាំងពីក្មេងមក មានទេបងស្រី?

ខ៖ មានតើ ភាគច្រើនច្រៀងតាមបទមនោសញ្ចេតនា តែបានតែមួយម៉ាត់ពីរម៉ាត់អីនឹង បើអោយ ច្រៀងតាមអោយចប់នោះមិនចេះ ច្រៀងតាមបានតិចតួចនឹង។

ក៖ ហើយអញ្ចឹង តើនៅក្នុងក្រុមគ្រួសាររបស់បងស្រី មាននរណាដែលគាត់ចេះលេងឧបករណ៍ភ្លេងខ្មែរ ឬភ្លេងសម័យទេ?

ខ៖ នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំគ្មានអ្នកចេះលេងឧបករណ៍ភ្លេងទេ។

ក៖ ហើយអញ្ចឹង សំរាប់ផ្ទះបងស្រី មានលក្ខណៈយ៉ាងដូចម៉េចដែរ កាលដែលបងស្រីនៅក្មេង?

ខ៖ ផ្ទះកាលនៅពីក្មេងនឹង ផ្ទះតូច។

ក៖ ហើយអញ្ចឹង ផ្ទះនឹងមានលក្ខណៈជាផ្ទះខ្ពស់ ឬក៏ជាផ្ទះតៀមជាប់នឹងដី?

ខ៖ ជាផ្ទះតៀមជាប់នឹងដី។

ក៖ ហើយអញ្ចឹង សំរាប់ផ្ទះនឹង បងស្រីធ្វើដោយខ្លួនឯង
ឬមួយបងស្រីជួលអោយគេធ្វើអោយ?

ខ៖ ផ្ទះនឹងខ្ញុំធ្វើដោយខ្លួនឯង។

ក៖ ហើយអញ្ចឹង សំរាប់ឧបករណ៍ដែលយកមកធ្វើផ្ទះនឹងមានអ្វីខ្លះដែរបងស្រី?

ខ៖ មានឬស្សី ដើមដូង ដើមត្នោត ដែកគោល ញញួរ ពូថៅ។

ក៖ ហើយអញ្ចឹង សំរាប់ផ្ទះនឹង
តើនរណាគេដែលជាអ្នកបង្រៀនបងស្រីអោយធ្វើផ្ទះមួយនឹង?

ខ៖ ផ្ទះនឹងបងប្អូនជីដូនមួយរបស់ខ្ញុំគាត់អ្នកមកធ្វើអោយ យើងទៅរកគាត់អោយមកជួយ។

ក៖ អូ! អញ្ចឹងបងប្អូនជីដូនមួយរបស់បង
គាត់ជាអ្នកជួយប្រាប់ណែនាំអោយបងធ្វើផ្ទះមួយនឹង។
ហើយអញ្ចឹងបងស្រីមានដូចជាជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្តៅ
ជំនាញធ្វើស្ករត្នោត ឬមួយជំនាញត្បាញក្រមា?

ខ៖ គ្មានទេ មិនដែលចេះធ្វើចឹងទេ។

ក៖ ហើយអញ្ចឹង
បងស្រីធ្លាប់មានពេលដែលលំបាកជាងគេនៅក្នុងជីវិតរបស់បងស្រីដែរឬទេ?

ខ៖ ពេលដែលលំបាកជាងគេនៅក្នុងជីវិតមានតើ។

ក៖ តើពេលណាដែលបងគិតថាជីវិតបងស្រីលំបាកជាងគេ?

ខ៖ នៅពេលដែលខ្ញុំមានប្តីជាពេលដែលខ្ញុំលំបាកជាងគេ
លំបាកដោយសារយើងគ្មានយើងអីនឹងណា យើងក្រ។

ក៖ ហើយអញ្ចឹងបងស្រីបានឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរ?

ខ៖ ឆ្លងកាត់ដោយ ថាយើងគ្មាន យើងទៅធ្វើអីក៏មិនបាន ទៅរកអីក៏វាមិនបាន ពិបាកអត់។

កៈ ហើយអញ្ចឹង បងស្រីធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតទេ
ដូចជារៀបអាពាហ៍ពិពាហ៍កូនចៅ ឬមួយបងប្អូន
ឬមួយមានកម្មវិធីបុណ្យទាននៅក្នុងផ្ទះអីចឹង?

ខៈ អត់ទាន់មានទេ កូនចៅទាន់រៀបការនៅឡើយទេ
ចឹងហើយបុណ្យទានក៏មិនទាន់បានធ្វើអោយបានធំដុំនៅឡើងទេ។

កៈ ហើយអញ្ចឹង
សំរាប់បងស្រីធ្លាប់មានសេចក្តីសង្ឃឹមថាពេលដែលបងស្រីធំឡើងបងស្រីចង់ធ្វើអ្វីមួយទេ?

ខៈ ចាំ! ធ្លាប់មានតើ កាលពីនៅក្មេងធ្លាប់ស្រមៃថា ពេលធំឡើងចង់ធ្វើជាជាងសំអាងការ
តែដល់ឥឡូវវាហួសពេលហើយ ដោយសារយើងក្រគ្មានលទ្ធភាពនឹងធ្វើវាទេ។

កៈ ហើយអញ្ចឹង សំរាប់ចុងក្រោយនេះ
បើសិនជាបងស្រីចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយរបស់បង
តើបងស្រីនឹងផ្តាំផ្ញើរអ្វីខ្លះទៅកាន់ពួកគេ?

ខៈ ខ្ញុំចង់ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយ អោយប្រឹងប្រែងរកស៊ីអោយមានបាន
កុំអោយក្រលំបាកដូចខ្ញុំទៀត។

កៈ ហើយអញ្ចឹង បើបងស្រីចង់អោយពួកគាត់ចៀសវាង
តើបងស្រីចង់អោយពួកគាត់ចៀសវាងពីអ្វីខ្លះដែរបងស្រី?

ខៈ ខ្ញុំចង់អោយពួកគេចៀសវាងអោយឆ្ងាយពីគ្រឿងញៀន ហើយនឹងល្បែងស៊ីសង
ហើយអោយចេះគោរពចាស់ទុំ កុំអោយកោងកាង មានរឿងឈ្លោះប្រកែកគ្នា
អោយចេះសន្សំសុខ កុំសន្សំទុក្ខ។

កៈ ហើយអញ្ចឹង
ជាចុងក្រោយខ្ញុំសូមអរគុណបងស្រីយ៉ាងខ្លាំងដែលបងស្រីបានអោយពេលវេលា
សំរាប់អោយខ្ញុំបានសម្ភាសន៍បងស្រីអំពីខ្សែជីវិតរបស់បងស្រី ហើយខ្ញុំសូមជូនពរបងស្រី
សូម អោយបងស្រីមានសុខភាពល្អ កំលាំងមាំមួន ហើយជៀសផុតពីជម្ងឺទាំងឡាយ
ហើយថាតាមរយៈ ការសម្ភាសន៍របស់បងស្រីនឹងជួយកូនចៅជំនាន់ក្រោយរបស់បងស្រី
រៀនពីខ្សែជីវិតបងស្រី ហើយថាពួកគេនឹងចងចាំបងស្រី
ហើយនឹងយកបទពិសោធន៍របស់បងស្រី ដើម្បីអនុវត្តន៍នៅក្នុងជីវិតរបស់ពួកគេ
ដើម្បីជៀសផុតពីទុក្ខលំបាកទាំងអស់នឹង។ អញ្ចឹងអរគុណច្រើន បងស្រី។